OFFICE OF THE COMPLIANCE ADVISOR OMBUDSMAN (CAO)
2121 PENNSYLVANIA AVENUE, NW
WASHINGTON, DC 20433, USA
TELEPHONE: +1-202-473-1973
FACSIMILE +1-202-522-7400
CAO@worldbankgroup.org

## សេចក្តីថ្លែងព័ត៌មាន

### ការឯកភាពព្រមព្រៀងគ្នា ដែលសម្រេចបានតាមរយៈការសម្របសម្រួល រវាងសហគមន៍មូលដ្ឋាន និង ក្រុមហ៊ុន ទាក់ទងនឹងផលប៉ះពាល់នៃចំការកៅស៊ូ ក្នុងខេត្តរតនគិរី

ទីក្រុងវ៉ាស៊ីនតោន ឌីស៊ី ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥៖ ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (ស៊ីអេអូ) ដែលជាយន្តការដោះស្រាយបណ្តឹងសារទុក្ខឯករាជ្យ សម្រាប់សារជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដែលជាសាខាវិស័យឯកជនរបស់ក្រុមធនាគារពិភពលោក កំពុងដោះស្រាយពាក្យបណ្តឹងមួយ ដែលធ្វើឡើងដោយប្រជាពលរដ្ឋរងផលប៉ះពាល់ក្នុងមូលដ្ឋាន នៅខេត្តរតនគិរី ព្រះរាជាណាចក្រកម្ពុជា ទាក់ទងនឹងក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ (HAGL) ដែលធ្វើប្រតិបត្តិការចំការកៅស៊ូក្នុងតំបន់នេះ។

យោងតាមឯកសាររបស់ IFC ក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ គឺជាវិនិយោគិនមួយនៃក្រុមហ៊ុនសហគ្រាសវិនិយោគវៀតណាមចំកាត់។ IFC បានវិនិយោគប្រាក់ចំនួន ១២លានដុល្លាសហរដ្ឋអាមេរិក ដែលថវិកានេះគ្រប់គ្រងដោយក្រុមហ៊ុនជ្រេហ្គិនខាភិថលម៉ាណេជមិន ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធមួយរបស់ដ្រាហ្គិនខាភិថលគ្រុប។

ពាក្យបណ្តឹងត្រូវបានធ្វើឡើងដោយប្រជាពលរដ្ឋរងផលប៉ះពាល់ក្នុងមូលដ្ឋាន ក្នុងខែកុម្ភៈ ឆ្នាំ២០១៤ និងបានលើកឡើងនូវការព្រួយបារម្ភមួយចំនួនទាក់ទងនឹងការបាត់បង់ដីធ្លី និងផលប៉ះពាល់ទៅលើជីវភាពរស់នៅ ក្នុងភូមិចំនួន១៧ ក្បែរកន្លែងដែលក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ ធ្វើប្រតិបត្តិការ។ ដើមបណ្តឹងបានស្នើសុំឱ្យរក្សាការសម្ងាត់។ ក្នុងខែមេសា ឆ្នាំ២០១៤ អ្នកតំណាងសហគមន៍រងផលប៉ះពាល់ និង ក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ បានជ្រើសរើសចូលរួមក្នុងដំណើរការដោះស្រាយវិវាទ ដែលសម្របសម្រួលដោយការិយាល័យស៊ីអេអូ។

ចាប់តាំងពីឆ្នាំ២០១៤ ការិយាល័យស៊ីអេអូ បាននិងកំពុងសម្របសម្រួលកិច្ចប្រជុំនានា រវាងអ្នកតំណាងសហគមន៍ អង្គការមិនមែនរដ្ឋាភិបាលដែលគាំទ្រដល់សហគមន៍ និងបុគ្គលិកក្រុមហ៊ុន។ ក្នុងខែមករា ឆ្នាំ២០១៥ ភាគីបានអនុម័តទៅលើកម្រងវិធានមូលដ្ឋានមួយចំនួន។ មានកិច្ចព្រមព្រៀងបន្ថែមទៀតដែលសម្រេចបានក្នុងខែកក្កដា និង ខែកញ្ញា ឆ្នាំ២០១៥ រវាងក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ និង សហគមន៍រងផលប៉ះពាល់។

ដើម្បីអនុវត្តកិច្ចព្រមព្រៀងមួយដែលសម្រេចបាន នឹងមានការប្រារព្ធពិធីមួយក្នុងក្រុងបានលុង នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ដែលមានការចូលរួមពីអភិបាលរងខេត្តរតនគិរី អនុប្រធានក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ

អ្នកតំណាងសហគមន៍ ទីប្រឹក្សារបស់សហគមន៍ ព្រមទាំង ប្រធានការិយាល័យស៊ីអេអូ និងជាអនុប្រធានក្រុមធនាគារពិភពលោក។

ក្នុងចំណោមកិច្ចព្រមព្រៀងដែលសម្រេចបាន គឺជាការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុនមិនធ្វើការអភិវឌ្ឍន៍ទៅលើផ្ទៃដីបន្ថែម និង ធ្វើការចរចារទៅលើសំណង ឬ ប្រគល់ដីត្រឡប់មកវិញ ក្នុងករណីដែលរកឃើញថាក្រុមហ៊ុនបានអភិវឌ្ឍន៍ទៅលើដីរបស់សហគមន៍។ ភាគីបន្តជួបប្រជុំគ្នា និងពិភាក្សាអំពីបញ្ហាដែលពួកគេមានការព្រួយបារម្ភដោយមានការសម្របសម្រួលពីការិយាល័យស៊ីអេអូ។ សេចក្តីលម្អិតអំពីកិច្ចព្រមព្រៀង ដែលរួមមានសេចក្តីថ្លែងការណ៍រួមរបស់ភាគី និង លិខិតពីក្រុមហ៊ុន ដែលគូសបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់ពួកគេ អាចរកបាននៅឯគេហទំព័រ៖ www.cao-ombudsman.org។

ការិយាល័យស៊ីអេអូ បានបន្តជម្រាបជូនរាជរដ្ឋាភិបាលកម្ពុជាអំពីការផ្តល់ជំនួយរបស់ខ្លួនដល់ភាគី ដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហា និង បានជួបជាមួយអ្នកតំណាងនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងមហាផ្ទៃ និង មន្ទីរដោយឡែកពីគ្នាដែលជាខ្សែបណ្តោយក្រសួងនៅកម្រិតថ្នាក់ខេត្ត ដែលរួមមានជាអាទិ៍ សាលាខេត្តរតនគិរី និង អាជ្ញាធរមូលដ្ឋាននៅកម្រិតថ្នាក់ស្រុក ឃុំ និងភូមិ។

ព័ត៌មានលម្អិតបន្ថែមអំពីករណីនេះ អាចរកបាននៅឯគេហទំព័រ៖ www.cao-ombudsman.org។

**ព័ត៌មានទំនាក់ទំនងផ្នែកប្រព័ន្ធផ្សព្វផ្សាយរបស់ការិយាល័យស៊ីអេអូ ក្នុងទីក្រុងវ៉ាស៊ីនតោន ឌីស៊ី៖**

Emily Horgan
ទូរស័ព្ទ៖ +1.202.473.8353
អ៊ីមែល៖ ehorgan@worldbankgroup.org

---

**អំពីការិយាល័យស៊ីអេអូ៖**

*ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (ស៊ីអេអូ) គឺជាយន្តការបណ្តឹងសារទុក្ខឯករាជ្យរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និង ទីភ្នាក់ងារធានាការវិនិយោគពហុភាគី (MIGA) ដែលជាសាខាផ្នែកវិស័យឯកជនរបស់ក្រុមធនាគារពិភពលោក។ ការិយាល័យស៊ីអេអូ រាយការណ៍ដោយផ្ទាល់ជូនដល់ប្រធានក្រុមធនាគារពិភពលោក។ អាណត្តិការងាររបស់ការិយាល័យស៊ីអេអូ គឺធ្វើការដោះស្រាយពាក្យបណ្តឹងពីប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោងរបស់ IFC និង MIGA ក្នុងលក្ខណៈមួយដែលប្រកបដោយភាពយុត្តិធម៌ អព្យាក្រឹត្យ និង មានភាពស្ថាបនា ក្នុងគោលដៅលើកកម្ពស់លទ្ធផលផ្នែកសង្គម និង បរិស្ថានជាក់ស្តែងនៅមូលដ្ឋាន។*